ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**

លេខៈ ៤៣៤ សណ៣/គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៣

**គោរពជូន**

**ឯកឧត្តមអភិបាលរាជធានី ខេត្ត**

**កម្មវត្ថុ** ៖ សំណើសុំចាត់មន្ត្រីអញ្ជើញចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្តីពីគោលការណ៍ណែនាំសម្រាប់ការរៀបចំកសាងផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ន នៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**យោង** ៖ ផែនការសកម្មភាព និងថវិកាឆ្នាំ២០១៣ របស់លេខាធិការដ្ឋាន គ.ជ.អ.ប ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា លេខាធិការដ្ឋាន គ.ជ.អ.ប នឹងរៀបចំសិក្ខាសាលាមួយ ដើម្បីផ្សព្វផ្សាយដល់ថ្នាក់មូលដ្ឋាន យល់ដឹងពីឯកសារបច្ចេកទេសស្តីពីគោលការណ៍ណែនាំសម្រាប់ការរៀបចំកសាងផែនការត្រៀមបម្រុងឆ្លើយតបគ្រោះ អាសន្ន នៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងជាផែនទីបង្ហាញផ្លូវក្នុងការត្រៀមបម្រុងការកាត់បន្ថយគ្រោះមហន្តរាយ ។ សិក្ខាសាលានឹងប្រព្រឹត្តចាប់ពីថ្ងៃទី**២៨ដល់ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៣** នៅខេត្តបាត់ដំបង (ទីកន្លែងបណ្តុះបណ្តាល នឹងជម្រាបជូនតាមក្រោយ) ។ សូមជូនភ្ជាប់មកជាមួយនូវរបៀបវារៈសម្រាប់សិក្ខាសាលា ។

អាស្រ័យហេតុនេះ លេខាធិការដ្ឋាន គ.ជ.អ.ប សូមស្នើឯកឧត្តមចាត់មន្ត្រីចូលរួមសិក្ខាសាលានេះដូចមានខាងក្រោមៈ

| | |
|---|---|
| -អភិបាលរងខេត្ត (ដែលទទួលបន្ទុកការងារគ្រោះមហន្តរាយ) | ចំនួន០១រូប |
| -ទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់រាជធានី ខេត្ត | ចំនួន០១រូប |
| -មន្ត្រីបច្ចេកទេសនៃលេខាធិការដ្ឋានគ្រោះមហន្តរាយខេត្ត | ចំនួន០២រូប |

**បញ្ជាក់:** ប្រាក់បេសកកម្មសម្រាប់អ្នកដែលបានចូលរួមសិក្ខាសាលា និងអ្នកបើកបររបស់ផអព (អ្នកបើកបរមិនលើសពីរនាក់) ជាបន្ទុករបស់លេខាធិការដ្ឋាន គ.ជ.អ.ប ។ ចំពោះថ្លៃធ្វើដំណើរ នឹងផ្តល់ជូនចំពោះអ្នកចូលរួមដែលមិនអាចធ្វើដំណើរតាមរថយន្តរបស់កម្មវិធីដោយផ្តល់តាមអត្រារបស់លេខាធិការដ្ឋាន គ.ជ.អ.ប ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមចាត់មន្ត្រីចូលរួមសិក្ខាសាលានេះតាមការគួរ ។
សូមឯកឧត្តមទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ ។

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**
**ស្តីទី**

ង៉ាន់ ចំរើន

លោក នុត លីដា

ទំនាក់ទំនង: ០១២ ២៧៦ ២០៣